# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៤-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៨៥ ស្តីពី ការតែងតាំងទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២ រូប ៧៥៣៥

១៤-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៨៦ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ចំនួន ០៦ នាក់ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃអង្គភាពប្រឆាំងអំពើពុករលួយ ៧៥៣៦

១៤-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៨៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ នាយទាហានជាន់ខ្ពស់ ចំនួន ០៤ រូប ៧៥៣៨

១៤-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៨៨ ស្តីពី ការតែងតាំងឯកឧត្តម **ឈេប សាម្ភុត** ជាអគ្គលេខាធិការគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧៥៣៩

១៤-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៨៩ ស្តីពី ការតែងតាំងឯកឧត្តម **អោត ម៉ូរ៉ា** ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃប្រៃសណីយ៍កម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ៧៥៤០

១៤-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៩០ ស្តីពី ការដកឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ និង លុបឈ្មោះចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ពីឧត្តមសេនីយ៍ទោ **ខូច ផល្លាមុត្រ** ៧៥៤១

១៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៩១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឥស្សរជនអន្តរជាតិ ចំនួន ០៧ រូប ៧៥៤២

១៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៩២ ស្តីពី ការដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៣ រូប ៧៥៤៣

១៦-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៩៣ ស្តីពី ការតែងតាំងឯកឧត្តម **លឹម ម៉ៅ** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧៥៤៤

១៩-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៩៤ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ដល់នាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ១៧៨ រូប ៧៥៤៥

១៩-៩-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៩១១/៨៩៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៦ រូប ៧៥៥២

## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

២២-៩-២០១១ -អនុក្រឹត្យលេខ ២១៥ អនក្រ.បក ស្តីពី ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ ២០១១-២០១៤ ៧៥៥៣

២២-៩-២០១១ -អនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពី ការបង្កើត ៤ ស្នងការដ្ឋាន ដាក់ចំណុះបញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន ៧៥៥៦

២៣-៩-២០១១ -អនុក្រឹត្យលេខ ២១៧ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៧៥៥៩

៣០-៩-២០១១ -អនុក្រឹត្យលេខ ២១៨ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ ទំហំ ១.៩១៥.៧០ ហិកតា ស្ថិតក្នុងសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និង គ្រួសារ ៧៥៦១

២២-៩-២០១១ -អនុក្រឹត្យលេខ ១០៨២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៥៦៥

២២-៩-២០១១ -អនុក្រឹត្យលេខ ១០៨៣ អនក្រ.តត ស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយ ៧៥៦៦

២២-៩-២០១១ -អនុក្រឹត្យលេខ ១០៨៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៥៦៨

២២-៩-២០១១ -អនុក្រឹត្យលេខ ១០៨៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧៥៦៩

២២-៩-២០១១ -អនុក្រឹត្យលេខ ១០៨៦ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ៧៥៧០

២៣-៩-២០១១ -អនុក្រឹត្យលេខ ១០៨៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៥៧២

២៣-៩-២០១១ -អនុក្រឹត្យលេខ ១០៨៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧៥៧៣

២៣-៩-២០១១ -អនុក្រឹត្យលេខ ១០៨៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៥៧៤

២៣-៩-២០១១ -អនុក្រឹត្យលេខ ១០៩០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧៥៧៥

៣០-៩-២០១១ -អនុក្រឹត្យលេខ ១០៩១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៧៥៧៦

៣០-៩-២០១១ -អនុក្រឹត្យលេខ ១០៩២ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៧៥៧៧

៣០-៩-២០១១ -អនុក្រឹត្យលេខ ១០៩៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៧៥៧៨

## III. ការងារបណ្ដាក្រសួង

### ១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៨-៩-២០១១ -ប្រកាសលេខ ៨២០ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្ព័រតិច អ៊ិនឌីសស្ទ្រីយ៍ បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៥៨១

០៨-៩-២០១១ -ប្រកាសលេខ ៨២១ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន និច-ធី អឺភែរ៉ល (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៥៨៥

០៨-៩-២០១១ -ប្រកាសលេខ ៨២២ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វូស៊ីន ស៊្ទីល ប៊ីលឌីង បង្កើតរោងចក្រ ផលិតសម្ភារៈសំណង់ ពីដែក ៧៥៨៩

០៨-៩-២០១១ -ប្រកាសលេខ ៨២៣ ឧរថ.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហុងកុង វីនហ្វ៊ែរ ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៧៥៩៣

### ២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៤-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣៤៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លី ត្រេហ្សឺរ អ៊ឹមផត អិចផត** ៧៥៩៧

១៤-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣៤៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចូ.ឆាយ.អិម.អ៊ិនវេសមេន** ៧៥៩៩

១៤-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣៤៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រូស្ស អេស៊ា ធូរ** ៧៦០១

១៤-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣៤៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គីម ថា អគិចឡូន៍ អ៊ឹមផត អិចផត** ៧៦០៣

១៤-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣៤៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាយណា (ខេមបូឌា) យ៉ាញ អ៊ិនវេសមេន ខនសាល់ធីង លីមីធីត** ៧៦០៥

១៤-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣៦៤ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តំកល់ ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ហ្វ័រឈូន ហ្វេសិន លីមីធីត** ៧៦០៧

១៥-៩-២០១០ -លិខិតបញ្ជាក់លេខ ៤៣៦៦ ពណ.ចបព ស្ដីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តំកល់ ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ច័ន្ទសុភា អគិចឡូន៍** ៧៦០៩

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស គម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២រូប÷

១. ឯកឧត្តម **សួន លាងហៃ** មានឋានៈស្មើ **រដ្ឋលេខាធិការ**

២. លោកជំទាវ **នែម នាង** មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរណ.១១០៩.៩០២

លេខៈ ៧៥០០.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១*

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការចំនួន ០៦ នាក់ ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៃអង្គភាពប្រឆាំងអំពើពុករលួយ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១១ តទៅ ៖

| ល.រ | នាមនិងគោត្តនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | ឋានន្តរស័ក្តិនិងថ្នាក់ |
|---|---|---|---|---|
| ១ | អ៊ូ ស៊ីថា | ស | ០១.០៧.១៩៨៤ | អនុមន្ត្រីថ្នាក់លេខ ១១ |
| ២ | ឈិត សុគន្ធី | ប | ១៤.០៩.១៩៨២ | អនុមន្ត្រីថ្នាក់លេខ ១១ |
| ៣ | កេត វិចិត្រ | ប | ១៩.០៣.១៩៨១ | អនុមន្ត្រីថ្នាក់លេខ ១១ |
| ៤ | ញ៉ី បញ្ញារិទ្ធ | ប | ១៤.១២.១៩៨៦ | អនុមន្ត្រីថ្នាក់លេខ ១១ |
| ៥ | លី ជាវុធ | ប | ១៣.០៥.១៩៨៣ | អនុមន្ត្រីថ្នាក់លេខ ១១ |

| | | | | |
|---|---|---|---|---|
| ៦ | **ភឹម ភឹក** | ប | ៣០.០៨.១៩៨៥ | អនុមន្ត្រីថ្នាក់លេខ ១១ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពារស. ១១០៩.៩០៣*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១*

លេខ: ៥៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានជាន់ខ្ពស់ ចំនួន០៤រូប មានគុណបំណាច់និងស្នាដៃល្អផ្ញើមក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ នៅសមរភូមិមុខ ជាពិសេសក្នុងការដឹកនាំបញ្ជាប្រយុទ្ធ និងត្រៀមប្រយុទ្ធការពារបូរណភាពទឹកដីអស់ពីកម្លាំងកាយចិត្ត ទទួលបានជោគជ័យ

នូវ

## គ្រឿងឥស្សរិយយស ជាតូបការ :

១-ឧត្តមសេនីយ៍ឯក សៀក សុជាតិ អគ្គលេខ ០០៥២០៤
២-ឧត្តមសេនីយ៍ឯក ត្រាំ ផេង អគ្គលេខ ០០០៤២៨
៣-ឧត្តមសេនីយ៍ឯក ចាប ភក្តី អគ្គលេខ ០០០៤៣០
៤-ឧត្តមសេនីយ៍ឯក ឡាញ់ កៅ អគ្គលេខ ០០០១១២

៣៦៧. ១១០៩.៩០៤

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១

ប្រ.ះ:៩៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កញ្ញា ឆ្នាំ២០១១
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៩៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្តយ ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតំលៃទីក្រុងស្អាត
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** ត្រូវបានតែងតាំង **ឯកឧត្តម ណេប សាមុត** ជាអគ្គលេខាធិការគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ១១០៩.៩០៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១

លេខ: ៧៥៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល**

**ស៊ីយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៨៨៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង ឯកឧត្តម **អោក ប៊ូរ៉ា** ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃប្រៃសណីយ៍កម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦ល.១១០៩.៩០៤

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១

លេខ: ៨៤៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៩០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដកឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ និងលុបឈ្មោះចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ពីឧត្តមសេនីយ៍ទោ **ខុច ផល្លាបុត្រ** អត្តលេខ ០០៣៤០៧ ។

**មាត្រា ២** : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

មាស. ១១០៩. ៩០៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១

លេខៈ ៩៤៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរង ...រាជរដ្ឋាភិបាល**

**... សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឥស្សរជនអន្តរជាតិចំនួន ០៧រូប ដែលបានចូលរួមចំណែកយ៉ាងសកម្ម
ក្នុងសកម្មភាពរបស់ចលនាអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិអាស៊ីប៉ាស៊ីហ្វិកនៅកម្ពុជា

នូវ

ក- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេរីវឌ្ឍន៍** ÷

១. ឯកឧត្តម **Jusuf Kalla**

២. ឯកឧត្តម **Jose De VENECIA**

ខ- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា** ÷

១. ឯកឧត្តម **CHUNG Eui-yong**

២. ឯកឧត្តម **Mushahid HUSSAIN SAYED**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** –

១. ឯកឧត្តម **Yasril Ananta Baharuddin**

២. ឯកឧត្តម **Iskandar Mandji**

៣. ឯកឧត្តម **Dato Seri Shahidan bin KASSIM**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល. ១១០៩.៩០៤

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១

លេខ ...៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែកញ្ញា ឆ្នាំ២០១១

អគ្គលេខាធិការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៩៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ:

១-លោកស្រីឧត្តមសេនីយ៍ត្រី **ថន សុវណ្ណចំន្ទខេមរ៉ា** អត្តលេខ ៥៤៥៦៣

២-លោកឧត្តមសេនីយ៍ត្រី **សុន ឌុន្សី** អត្តលេខ ០៥៦៧

៣-លោកឧត្តមសេនីយ៍ត្រី **អ៊ុន ចន្ថា** អត្តលេខ ២០៤១៣

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល. ១១០៩.៩០៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១

បានឃើញថាត្រឹមត្រូវតាមច្បាប់ដើម លេខ ...៨០.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៤៩៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្តម **លឹម ម៉ៅ** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

ចាស. ១១០៩.៩១០

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១១

លេខ ៤៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ម៉ែង សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៧៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ដល់ នាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៖

**ក.ដំឡើងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក :**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | **ប៉ុល** | **និត្យ** | អត្តលេខ 000៤៥៣ |
| ២-ឧត្តមសេនីយ៍ទោ | **សេន** | **គូម៉ារី** | អត្តលេខ 00៤២២៥ |
| ៣-ឧត្តមសេនីយ៍ទោ | **ឈឹម** | **សាឧុធ** | អត្តលេខ 00១៩៤៨ |
| ៤-ឧត្តមសេនីយ៍ទោ | **ផុន** | **សាវ៉ាត** | អត្តលេខ 0000៩៥ |
| ៥-ឧត្តមសេនីយ៍ទោ | **ម៉ម** | **យឿន** | អត្តលេខ 000៧២៤ |
| ៦-ឧត្តមសេនីយ៍ទោ | **ចាន់** | **នន់ឋិឡា** | អត្តលេខ 00៣៤៥៩ |
| ៧-ឧត្តមសេនីយ៍ទោ | **សូ** | **សុវណ្ណមុនី** | អត្តលេខ 000៧៨៧ |
| ៨-ឧត្តមសេនីយ៍ទោ | **ឆួន** | **សំអាន** | អត្តលេខ 00២១៥៦ |
| ៩-ឧត្តមសេនីយ៍ទោ | **ព្រុំ** | **ជុំធីណា** | អត្តលេខ 00៤៤២៧ |
| ១០-ឧត្តមសេនីយ៍ទោ | **ព្រហ្ម** | **មរណៈ** | អត្តលេខ 000១៨៨ |
| ១១-ឧត្តមសេនីយ៍ទោ | **ចាប** | **ទ៉ាន្នី** | អត្តលេខ 000២៨៧ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១២-ឧត្តមសេនីយ៍ទោ សំរិទ្ធ ហ៊ុន អត្តលេខ ០០០១៦៦
១៣-ឧត្តមសេនីយ៍ទោ រ៉េត ស៊ីថា អត្តលេខ ០០៣៣៣១
១៤-ឧត្តមសេនីយ៍ទោ សួស យ៉ារ៉ា អត្តលេខ ០៣២៦៦៨
១៥-ឧត្តមសេនីយ៍ទោ លន់ សុធី អត្តលេខ ០១៩៧២០
១៦-ឧត្តមសេនីយ៍ទោ ហ៊ឹម រិន អត្តលេខ ០០២៣៥៣
១៧-ឧត្តមសេនីយ៍ទោ ចាន់ សារី អត្តលេខ ០០៣៣៣៤

**ខ.ដំឡើងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ៖**

១-ឧត្តមសេនីយ៍ត្រី មាស សុខុន អត្តលេខ ០០១២១៩
២-ឧត្តមសេនីយ៍ត្រី ស្រួល សុខជា អត្តលេខ ០១១៧៧៨
៣-ឧត្តមសេនីយ៍ត្រី សរ សារ៉ាន់ អត្តលេខ ០០៤០២៣
៤-ឧត្តមសេនីយ៍ត្រី ម៉ម គុណា អត្តលេខ ០០៤០៩៤
៥-ឧត្តមសេនីយ៍ត្រី ប្រុញ សត្តម៉ា អត្តលេខ ០០៤០៣៣
៦-ឧត្តមសេនីយ៍ត្រី ស៊ឹម សុគន្ធា អត្តលេខ ០០៤០២៤
៧-ឧត្តមសេនីយ៍ត្រី ស៊ិន សីន អត្តលេខ ០០២៤០១
៨-ឧត្តមសេនីយ៍ត្រី ឯម គន្ធា អត្តលេខ ០០៥២០២
៩-ឧត្តមសេនីយ៍ត្រី អ៊ុំ ស៊ីវណ្ណា អត្តលេខ ០០៣៤០១
១០-ឧត្តមសេនីយ៍ត្រី ឆេព មឿន អត្តលេខ ០០៣៤៦៤
១១-ឧត្តមសេនីយ៍ត្រី ស៊ួន សុខរ៉ា អត្តលេខ ០០៤០០៨
១២-ឧត្តមសេនីយ៍ត្រី ស៊ិន សារ៉េត អត្តលេខ ០៤៣៩៦១
១៣-ឧត្តមសេនីយ៍ត្រី ស៊ឹម ម៉ិនថន អត្តលេខ ០១៧៦៦១
១៤-ឧត្តមសេនីយ៍ត្រី ស៊ុន ហួរ អត្តលេខ ០២១១០៩
១៥-ឧត្តមសេនីយ៍ត្រី តាំក្រ គិរុណា អត្តលេខ ០០៣៧៦៩
១៦-ឧត្តមសេនីយ៍ត្រី សៀប ឆាត អត្តលេខ ០០៣៧៨៥
១៧-ឧត្តមសេនីយ៍ត្រី ឡួន ចែម អត្តលេខ ០០៤៦៣៣
១៨-ឧត្តមសេនីយ៍ត្រី គង់ សិទ្ធ អត្តលេខ ០០០៨៦១
១៩-ឧត្តមសេនីយ៍ត្រី ជា លីស្រ៊ុន អត្តលេខ ០១២១៧៤
២០-ឧត្តមសេនីយ៍ត្រី ម៉ែន សុខ អត្តលេខ ០០៤០៩៥
២១-ឧត្តមសេនីយ៍ត្រី ណាំ គិរុណា អត្តលេខ ០០៤០២៧
២២-ឧត្តមសេនីយ៍ត្រី សុខ វណ្ណា អត្តលេខ ០០៤០៦៧
២៣-ឧត្តមសេនីយ៍ត្រី គង់ ចាន់សារុធ អត្តលេខ ០២៧១៩៩
២៤-ឧត្តមសេនីយ៍ត្រី ធី សម្បត្តិ អត្តលេខ ០០៣៧៨៣
២៥-ឧត្តមសេនីយ៍ត្រី ឆា ប្រោន់ណា អត្តលេខ ០៤៣៩០៦
២៦-ឧត្តមសេនីយ៍ត្រី ប៊ិន បូនីបុត្រ អត្តលេខ ០៨៦៦៩០

២៧-ឧត្តមសេនីយ៍ត្រី **ហាយ វណ្ណឌី** អត្តលេខ ០២៨៤៨០
២៨-ឧត្តមសេនីយ៍ត្រី **ឡៅ គុងហាំង** អត្តលេខ ០៨៤៥៨៧
២៩-ឧត្តមសេនីយ៍ត្រី **នូ ប្រុសពៅ** អត្តលេខ ០១១៦១៨
៣០-ឧត្តមសេនីយ៍ត្រី **នួច ផល្លា** អត្តលេខ ០០៨០៣១
៣១-ឧត្តមសេនីយ៍ត្រី **ហាស គឹមហេង** អត្តលេខ ០៣៩៣២១
៣២-ឧត្តមសេនីយ៍ត្រី **ឈុន គឹមស្រ៊ុន** អត្តលេខ ០០២៧២៦
៣៣-ឧត្តមសេនីយ៍ត្រី **គិន សុខ** អត្តលេខ ០០០៥៨៨
៣៤-ឧត្តមសេនីយ៍ត្រី **ឡឹក សំបូរ** អត្តលេខ ០០១៦១៨
៣៥-ឧត្តមសេនីយ៍ត្រី **នួន សំអាត** អត្តលេខ ០០១៤៥៨
៣៦-ឧត្តមសេនីយ៍ត្រី **គុំ ម៉ុនថន** អត្តលេខ ០០០២២៣
៣៧-ឧត្តមសេនីយ៍ត្រី **គីម សុវណ្ណ** អត្តលេខ ០០១៤៧៣
៣៨-ឧត្តមសេនីយ៍ត្រី **សោម ឡាយ** អត្តលេខ ០០០៥៤៤
៣៩-ឧត្តមសេនីយ៍ត្រី **អ៊ុន សារុំ** អត្តលេខ ០០១៨៦៥
៤០-ឧត្តមសេនីយ៍ត្រី **អ៊ុក ហួច** អត្តលេខ ០០១៦៦៣
៤១-ឧត្តមសេនីយ៍ត្រី **បេង សត្ថារិទ្ធ** អត្តលេខ ០០៣៨៩៤
៤២-ឧត្តមសេនីយ៍ត្រី **សួស សុទ្ធ** អត្តលេខ ០០២២៧៨
៤៣-ឧត្តមសេនីយ៍ត្រី **ស៊ឹម សុភាព** អត្តលេខ ០១៥៦៥១
៤៤-ឧត្តមសេនីយ៍ត្រី **ប៉ុក ចាន់ដារ៉ា** អត្តលេខ ០០១៥៧០
៤៥-ឧត្តមសេនីយ៍ត្រី **នង ច័ន្ទដារ៉ា** អត្តលេខ ០០២៣៩០
៤៦-ឧត្តមសេនីយ៍ត្រី **ម៉ែន យន់** អត្តលេខ ០០១២១៤
៤៧-ឧត្តមសេនីយ៍ត្រី **អ៊ូ សុភី** អត្តលេខ ០០០៦០៣
៤៨-ឧត្តមសេនីយ៍ត្រី **កើត ប៉ូលីន** អត្តលេខ ០០១៨៦៤
៤៩-ឧត្តមសេនីយ៍ត្រី **ចាន់ សារ៉ាដ** អត្តលេខ ០០០២៤២
៥០-ឧត្តមសេនីយ៍ត្រី **ហ៊ុល សំអុន** អត្តលេខ ០០៩១០៧
៥១-ឧត្តមសេនីយ៍ត្រី **អ៊ុង សុវណ្ណ** អត្តលេខ ០០១៩៦៩
៥២-ឧត្តមសេនីយ៍ត្រី **សន វ៉ាត** អត្តលេខ ០០១៤៣១
៥៣-ឧត្តមសេនីយ៍ត្រី **សុខ ប៉ាង** អត្តលេខ ០០០៨៣៥
៥៤-ឧត្តមសេនីយ៍ត្រី **គីម វណ្ណា** អត្តលេខ ០១២៥០១
៥៥-ឧត្តមសេនីយ៍ត្រី **សៅ សៀប** អត្តលេខ ០០១៩៨៩
៥៦-ឧត្តមសេនីយ៍ត្រី **ឃី ណៃយ៉ា** អត្តលេខ ០១១៦៩៤
៥៧-ឧត្តមសេនីយ៍ត្រី **ខ៉េត ស្រៀង** អត្តលេខ ០០២៦៥០
៥៨-ឧត្តមសេនីយ៍ត្រី **ចាន់ រិទ្ធីឌី** អត្តលេខ ០១០២១១
៥៩-ឧត្តមសេនីយ៍ត្រី **ចោង ចាវរិទ្ធ** អត្តលេខ ០០៤១៣២



| | | | |
|---|---|---|---|
| ៦០-ឧត្តមសេនីយ៍ត្រី | **សុខ** | **សាយ** | អត្តលេខ ០០៤១៥៧ |
| ៦១-ឧត្តមសេនីយ៍ត្រី | **សំ** | **ចិន្តា** | អត្តលេខ ០០០៦៨២ |
| ៦២-ឧត្តមសេនីយ៍ត្រី | **អ៊ុង** | **ណារិទ្ធ** | អត្តលេខ ០០១៨៣៩ |
| ៦៣-ឧត្តមសេនីយ៍ត្រី | **សុខ** | **សុវណ្ណនិត** | អត្តលេខ ០១១៦១០ |
| ៦៤-ឧត្តមសេនីយ៍ត្រី | **អ៊ុក** | **ដារ៉ា** | អត្តលេខ ០១១៤៤៦ |

**គ.ដំឡើងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី :**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **ហ៊ុន** | **សារ៉េត** | អត្តលេខ ០០០៩៤០ |
| ២-វរសេនីយ៍ឯក | **ជា** | **ស្រេង** | អត្តលេខ ០០៤៨៩៨ |
| ៣-វរសេនីយ៍ឯក | **សុខ** | **ឡា** | អត្តលេខ ០០៣៥៥៤ |
| ៤-វរសេនីយ៍ឯក | **ឆ៊ាន់** | **សុភី** | អត្តលេខ ០០១៨៤៥ |
| ៥-វរសេនីយ៍ឯក | **ធន** | **ឡឿន** | អត្តលេខ ០០២១០៣ |
| ៦-វរសេនីយ៍ឯក | **ឌួន** | **សំអេក** | អត្តលេខ ០០២២៤៨ |
| ៧-វរសេនីយ៍ឯក | **ធូណាស់** | **ម៉ាន** | អត្តលេខ ០០១៩១២ |
| ៨-វរសេនីយ៍ឯក | **លី** | **ស៊ុន** | អត្តលេខ ០០៤៤១៥ |
| ៩-វរសេនីយ៍ឯក | **ចាន់** | **ប៊ុនហេង** | អត្តលេខ ០០៨៨២១ |
| ១០-វរសេនីយ៍ឯក | **អ៊ុយ** | **សុផាត** | អត្តលេខ ០០២២៤៣ |
| ១១-វរសេនីយ៍ឯក | **អ៊ុង** | **ជំនោរ** | អត្តលេខ ០០១១៩៨ |
| ១២-វរសេនីយ៍ឯក | **គឹម** | **ផាន** | អត្តលេខ ០០០៦៣៥ |
| ១៣-វរសេនីយ៍ឯក | **ពោជ** | **ខេង** | អត្តលេខ ០១៣៦៩៧ |
| ១៤-វរសេនីយ៍ឯក | **ជូ** | **សូរិយារ៉ុង** | អត្តលេខ ០០១៣៤៩ |
| ១៥-វរសេនីយ៍ឯក | **គង់** | **ប៊ុនធឿន** | អត្តលេខ ០០១៣៥៤ |
| ១៦-វរសេនីយ៍ឯក | **សែម** | **កេសរគន្ធ** | អត្តលេខ ០០១៦៨៦ |
| ១៧-វរសេនីយ៍ឯក | **ចេង** | **ហុង** | អត្តលេខ ០១៩៧១០ |
| ១៨-វរសេនីយ៍ឯក | **មិក** | **សាផាណារ៉េត** | អត្តលេខ ០០៣៣៨៦ |
| ១៩-វរសេនីយ៍ឯក | **ហេង** | **ឆាយ** | អត្តលេខ ០០៤១០៤ |
| ២០-វរសេនីយ៍ឯក | **មាស** | **ស៊ីផាន** | អត្តលេខ ០១៧២៦៥ |
| ២១-វរសេនីយ៍ឯក | **នួន** | **សុវណ្ណារ៉ា** | អត្តលេខ ០១០៩៩៧ |
| ២២-វរសេនីយ៍ឯក | **សុទ្ធ** | **ស៊ិនសំបូរ** | អត្តលេខ ០០៩៤៨២ |
| ២៣-វរសេនីយ៍ឯក | **សៅ** | **សុធារ៉ា** | អត្តលេខ ០២០៨៨២ |
| ២៤-វរសេនីយ៍ឯក | **ទី** | **សុវណ្ណ** | អត្តលេខ ០១១៩១៥ |
| ២៥-វរសេនីយ៍ឯក | **លឹម** | **ឆខាយ** | អត្តលេខ ០១៥៣០២ |
| ២៦-វរសេនីយ៍ឯក | **ឡាត់** | **ជឿន** | អត្តលេខ ០០៩៦១០ |
| ២៧-វរសេនីយ៍ឯក | **រស់** | **គង់** | អត្តលេខ ០០៨៨០២ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

| | | | |
|---|---|---|---|
| ២៨-វរសេនីយ៍ឯក | ផន | សុធាវី | អត្តលេខ ០០១២១១ |
| ២៩-វរសេនីយ៍ឯក | ស៊ឹម | សំអាត | អត្តលេខ ០០៨៧៩៨ |
| ៣០-វរសេនីយ៍ឯក | សៅ | ប្រាថ្នា | អត្តលេខ ០០១៧៧៣ |
| ៣១-វរសេនីយ៍ឯក | ស៊ុ | រឿង | អត្តលេខ ០០១៥៦២ |
| ៣២-វរសេនីយ៍ឯក | គង់ | ណោវ៉ាន់ | អត្តលេខ ០០១៥៨៩ |
| ៣៣-វរសេនីយ៍ឯក | ហេង | សារ៉ាន់ | អត្តលេខ ០២៥១២៦ |
| ៣៤-វរសេនីយ៍ឯក | ជា | សុផល | អត្តលេខ ០០០៧៨៩ |
| ៣៥-វរសេនីយ៍ឯក | ហៅ | សុវណ្ណា | អត្តលេខ ០០២០២០ |
| ៣៦-វរសេនីយ៍ឯក | ចាន់ | សោភ័ណ្ឌាគា | អត្តលេខ ០០៥១៩៨ |
| ៣៧-វរសេនីយ៍ឯក | ឡាយ | សុវណ្ណា | អត្តលេខ ០១៤៤៩៥ |
| ៣៨-វរសេនីយ៍ឯក | ហ៊ិន | សុផាត | អត្តលេខ ០១៦៩៩៩ |
| ៣៩-វរសេនីយ៍ឯក | ជា | ពៅ | អត្តលេខ ០១១០៤១ |
| ៤០-វរសេនីយ៍ឯក | ធឹម | សារៈ | អត្តលេខ ០០២១០៣ |
| ៤១-វរសេនីយ៍ឯក | ហេង | រស្មី | អត្តលេខ ០០២១១២ |
| ៤២-វរសេនីយ៍ឯក | ពេជ្រ | កល្យាណា | អត្តលេខ ០០៣៨៣៩ |
| ៤៣-វរសេនីយ៍ឯក | ស៊ុនី | ខេមរពិសិដ្ឋ | អត្តលេខ ០៤១៥៦៥ |
| ៤៤-វរសេនីយ៍ឯក | សាខុន | ណារិទ្ធ | អត្តលេខ ០១១៤៩៦ |
| ៤៥-វរសេនីយ៍ឯក | ស៊ីន | ធី | អត្តលេខ ០០១៤៥៥ |
| ៤៦-វរសេនីយ៍ឯក | កែវ | ឧត្តី | អត្តលេខ ០១១៧៣៨ |
| ៤៧-វរសេនីយ៍ឯក | ឈឿង | ផល្លាង | អត្តលេខ ០២៣០២០ |
| ៤៨-វរសេនីយ៍ឯក | ស៊ី | ឈាង | អត្តលេខ ០៣៧៥៨៩ |
| ៤៩-វរសេនីយ៍ឯក | គាន់ | សុផៃ | អត្តលេខ ០០៣៨៣៥ |
| ៥០-វរសេនីយ៍ឯក | អ៊ុំ | អ៊ឹម | អត្តលេខ ០០៩៣៧២ |
| ៥១-វរសេនីយ៍ឯក | ឡៅ | សុខហួរ | អត្តលេខ ០០៣២៩៤ |
| ៥២-វរសេនីយ៍ឯក | ប្រាក់ | រ៉ូ | អត្តលេខ ០១៧១៨៨ |
| ៥៣-វរសេនីយ៍ឯក | អ៊ុន | សំយុទ្ធ | អត្តលេខ ០១៥០០៣ |
| ៥៤-វរសេនីយ៍ឯក | ស្រី | សារូ | អត្តលេខ ០០៤២៤៨ |
| ៥៥-វរសេនីយ៍ឯក | ឡៀន | សោភ័ណខេមរ | អត្តលេខ ០០៩៣៣០ |
| ៥៦-វរសេនីយ៍ឯក | ផាង | គឹមគិច | អត្តលេខ ០១០៤៣១ |
| ៥៧-វរសេនីយ៍ឯក | អែម | សាម៉ុន | អត្តលេខ ០០១៨៩៤ |
| ៥៨-វរសេនីយ៍ឯក | សរ | ប៊ូរ៉ា | អត្តលេខ ០១៣៦១៩ |
| ៥៩-វរសេនីយ៍ឯក | ពៅ | យាន | អត្តលេខ ០១១៧០៧ |
| ៦០-វរសេនីយ៍ឯក | ច័ន្ទ | រដ្ឋា | អត្តលេខ ០៣២៦៦១ |

ROYAUME DU CAMBODGE • MINISTERE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៦១-វរសេនីយ៍ឯក | **កែវ** | **សុផល** | អត្តលេខ ០០៤០៤៩ |
| ៦២-វរសេនីយ៍ឯក | **ឃឹម** | **សាបាន** | អត្តលេខ ០០៨៥៤០ |
| ៦៣-វរសេនីយ៍ឯក | **ហៃ** | **ពូ** | អត្តលេខ ០១១៧៦៥ |
| ៦៤-វរសេនីយ៍ឯក | **អ៊ុន** | **រដ្ឋា** | អត្តលេខ ០៣២៦៤០ |
| ៦៥-វរសេនីយ៍ឯក | **ឡុង** | **ដា** | អត្តលេខ ០១៧៣៥០ |
| ៦៦-វរសេនីយ៍ឯក | **ឈុន** | **ពៅ** | អត្តលេខ ០១១៧៣៩ |
| ៦៧-វរសេនីយ៍ឯក | **អ៊ុក** | **សុខ** | អត្តលេខ ០១១៦៦០ |
| ៦៨-វរសេនីយ៍ឯក | **សំរិត** | **កុសល** | អត្តលេខ ២២៧២០៥ |
| ៦៩-វរសេនីយ៍ឯក | **តាង** | **សារុន** | អត្តលេខ ០០៨៣៤៩ |
| ៧០-វរសេនីយ៍ឯក | **ទូម** | **ឆាន** | អត្តលេខ ០៤៣៨៩៣ |
| ៧១-វរសេនីយ៍ឯក | **សុខ** | **ឡុង** | អត្តលេខ ០០៤០៦៥ |
| ៧២-វរសេនីយ៍ឯក | **សាឯម** | **សាផាត** | អត្តលេខ ០០៩៥៩៧ |
| ៧៣-វរសេនីយ៍ឯក | **ឈឹម** | **ឱនចិន្ត្រា** | អត្តលេខ ០១៨២៩៩ |
| ៧៤-វរសេនីយ៍ឯក | **ស្រួន** | **សុធី** | អត្តលេខ ០២១០៨២ |
| ៧៥-វរសេនីយ៍ឯក | **ហែម** | **ឡុងគង់** | អត្តលេខ ១៣៣៣១៩ |
| ៧៦-វរសេនីយ៍ឯក | **ពេជ្រ** | **សាមុំ** | អត្តលេខ ១៩០៧៧៥ |
| ៧៧-វរសេនីយ៍ឯក | **គី** | **ផាន់ណា** | អត្តលេខ ២២៧២៩៧ |
| ៧៨-វរសេនីយ៍ឯក | **ថោ** | **គឿន** | អត្តលេខ ០១១៧៦៨ |
| ៧៩-វរសេនីយ៍ឯក | **លី** | **តក្តី** | អត្តលេខ ០២១០៧៦ |
| ៨០-វរសេនីយ៍ឯក | **ប្រាក់** | **ដារ៉ា** | អត្តលេខ ០១០៨០៨ |
| ៨១-វរសេនីយ៍ឯក | **កុង** | **គង់** | អត្តលេខ ០៨៣២១៤ |
| ៨២-វរសេនីយ៍ឯក | **កៅ** | **សាវ៉ន** | អត្តលេខ ០១១៧២២ |
| ៨៣-វរសេនីយ៍ឯក | **ស្វាយ** | **ជូត** | អត្តលេខ ០០៤០៧១ |
| ៨៤-វរសេនីយ៍ឯក | **លឹម** | **រចនា** | អត្តលេខ ០០១០៦៤ |
| ៨៥-វរសេនីយ៍ឯក | **សំ** | **សារុន** | អត្តលេខ ០០៨៣៤៦ |
| ៨៦-វរសេនីយ៍ឯក | **យ៉ង់** | **សារឿន** | អត្តលេខ ០០៤០១៧ |
| ៨៧-វរសេនីយ៍ឯក | **សេង** | **សៀប** | អត្តលេខ ០០៤០៨៧ |
| ៨៨-វរសេនីយ៍ឯក | **យួន** | **សម្បត្តិ** | អត្តលេខ ០៦១៨៤៦ |
| ៨៩-វរសេនីយ៍ឯក | **ផាត់** | **សឿង** | អត្តលេខ ០២១១១៣ |
| ៩០-វរសេនីយ៍ឯក | **សាន់** | **ការិយ៉ា** | អត្តលេខ ០១១៧០១ |
| ៩១-វរសេនីយ៍ឯក | **សេក** | **សៀងហៃ** | អត្តលេខ ០១១៦៩៩ |
| ៩២-វរសេនីយ៍ឯក | **លៀង** | **សារុន** | អត្តលេខ ០១១៧៥៦ |
| ៩៣-វរសេនីយ៍ឯក | **ញ៉ែម** | **សារិន** | អត្តលេខ ០០៩០៨៨ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៩៤-វរសេនីយ៍ឯក **ឈី សុផេន** អត្តលេខ ១៦២៣៦០
៩៥-វរសេនីយ៍ឯក **គង់ ផាន** អត្តលេខ ០១១៦៨៦
៩៦-វរសេនីយ៍ឯក **ឈិញ សុវណ្ណា** អត្តលេខ ០២១១៣៩
៩៧-វរសេនីយ៍ឯក **សំរិទ្ធ សឿន** អត្តលេខ ០០៨០៥៦

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១១០៩.៩១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១

លេខ: ៩៦០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុករាជកិច្ចនិងរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១១/៩៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជនចំនួន ០៦ រូប ដែលបានបំពេញការងារសំខាន់ និងមានស្នាដៃ
ក្នុងការចូលរួមកសាង និងអភិវឌ្ឍប្រទេសជាតិ

នូវ

ក-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោក Nguyen Van Truong
២-លោកស្រី Pham Thi Lan

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-លោក Tran Van Nguyen
២-លោក Ly Quang Bich
៣-លោក Do Manh Hung
៤-លោក ស៊ិន សុកមុទ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាកស. ១១០៩.៩១៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១

លេខ:៨៦១ ប.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១១
**អគ្គលេខាធិការរង [illegible] រាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៥ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត នៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ផ្អែកតាមផែនការអន្តរស្ថាប័ន លេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១១ ស្តីពីកិច្ចការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិឆ្នាំ ២០១១ ២០១៤ ក្រសួងមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប

- យោងតាមការចាំបាច់ ។

**ស ម្រេ ច**

**មាត្រា ១.-** ត្រូវបានបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត នៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិឆ្នាំ ២០១១-២០១៤ អក្សរកាត់ " **គ.ស.អ** " ដែលមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២- ឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អនុប្រធាន

៣- ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៤- ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៥- ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៦- ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ សមាជិក

៧- ឯកឧត្តម នាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

៨- ឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងកងយោធពល ខេមរភូមិន្ទ និងជាមេបញ្ជាការកង រាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៩- អភិបាលនៃគណៈអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពគ្រប់រាជធានី ខេត្ត សមាជិក

**មាត្រា ២.-** គ.ស.អ មានភារកិច្ចទទួលខុសត្រូវ ដូចខាងក្រោម :

- សហការសម្របសម្រួល ជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប ) លើការងារសន្តិសុខទូទៅសម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ដែលរួមមាន : ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១ ការបោះឆ្នោតព្រឹទ្ធសភានីតិកាលទី ៣ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៣ ការបោះឆ្នោតតំណាងរាស្ត្រអាណត្តិទី ៥ និងការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌអាណត្តិទី ២ តាមនីតិកាល និងអាណត្តិនីមួយៗ ចាប់ផ្តើមពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ ។
- ចាត់តាំងកម្លាំងអនុវត្តច្បាប់ ពិសេសគណៈអភិបាល ឬគណៈបញ្ជាការឯកភាពគ្រប់រាជធានី ខេត្ត និងកងនគរបាលជាតិ ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ដោយសហការឱ្យបានជិតស្និទ្ធជាមួយនឹង គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីធានាឱ្យគ្រប់ដំណើរការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិនីមួយៗប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ គ្មានការបំភិតបំភ័យ ការគំរាមកំហែង និងអំពើហិង្សា ។
- ផ្សព្វផ្សាយព័ត៌មាន គោលការណ៍ណែនាំ និងវិធានការផ្សេងៗ ស្តីពីការងារសន្តិសុខបោះឆ្នោត ទៅដល់គ្រប់យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតទាំងអស់ ដើម្បីជ្រាប និងសហការអនុវត្ត ។
- ប្រមូលផ្តុំព័ត៌មាន ឬពាក្យប្តឹងទាក់ទងសន្តិសុខបោះឆ្នោត ពីបណ្តាស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ និងគណៈបញ្ជាការឯកភាពគ្រប់លំដាប់ថ្នាក់នៃរាជធានី ខេត្ត ដើម្បីពិនិត្យដោះស្រាយស្របតាមនីតិវិធី ។

- ពិនិត្យចាត់វិធានការ ប្រមូលផ្តុំ ចាត់តាំងកម្លាំងនគរបាលជាតិ ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទ ដោយប្រើប្រាស់សម្ភារៈ ឧបករណ៍ និងមធ្យោបាយគ្រប់ប្រភេទ របស់បណ្តាស្ថាប័ន និងអង្គភាពនីមួយៗផ្ទាល់ដែលមានស្រាប់ ដើម្បីរួមចំណែកអនុវត្តកិច្ចប្រតិបត្តិការការពារ សន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់សម្រាប់គ្រប់ដំណើរការ នៃការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ទាំងមូល ។

**មាត្រា ៣.-** ផ្អែកតាមផែនការអន្តរស្ថាប័នលេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១១ ស្តីពីកិច្ចការការពារសន្តិសុខសម្រាប់ការបោះឆ្នោត រវាងក្រសួងមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ប្រធាន គ.ស.អ ត្រូវពិនិត្យរៀបចំគម្រោងថវិកាបំប៉នដល់កម្លាំងការពារសន្តិសុខ និងថវិកាចំណាយលើការផ្គត់ផ្គង់ប្រេងឥន្ធនៈ សម្ភារៈឧបករណ៍ ឬមធ្យោបាយប្រើប្រាស់តាមការចាំបាច់ រួចស្នើសុំការអនុម័តពីរាជរដ្ឋាភិបាល ។

**មាត្រា ៤.-** គ.ស.អ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយ ជាជំនួយការការងារ និងមានសិទ្ធិប្រើប្រាស់ថវិកា និងត្រារបស់គណៈរដ្ឋមន្ត្រីសម្រាប់រាល់កិច្ចការក្នុងវិស័យរដ្ឋបាល ឬលិខិតស្នាមផ្លូវការផ្សេងៗរបស់ខ្លួន ។

**មាត្រា ៥.-** គ.ស.អ គឺជាសេនាធិការផ្ទាល់ជូនរាជរដ្ឋាភិបាល មានភារកិច្ចត្រូវរាយការណ៍ជាប្រចាំ អំពីស្ថានការណ៍សន្តិសុខបោះឆ្នោតទូទៅ និងការរៀបចំកម្លាំងភ្នាក់ងារសន្តិសុខបោះឆ្នោត សម្រាប់គ្រប់សម័យកាលនៃដំណើរការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិនីមួយៗ ។

**មាត្រា ៦.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ
- អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- សាលារាជធានី ខេត្ត ទាំង ២៤
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត ៤ស្នងការដ្ឋាន ជាក់ចំណុះបញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## <u>សម្រេច</u>

**មាត្រា១:** ត្រូវបានបង្កើតស្នងការដ្ឋានចំនួន ០៤ ជាក់ចំណុះ បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន ដូចខាងក្រោម៖

១- ស្នងការដ្ឋាន គ្រប់គ្រងកម្លាំង និងឃោសនា-ព័ត៌មាន

២- ស្នងការដ្ឋាន ភស្តុភារ

៣- ស្នងការដ្ឋាន បច្ចេកទេស

៤- ស្នងការដ្ឋាន ប្រតិបត្តិការ-វិស្វកម្ម

**មាត្រា២**: តួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងរបស់ ស្នងការដ្ឋានខាងលើ អាស្រ័យដោយក្រសួងការពារជាតិកំណត់ ។

**មាត្រា៣**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-ឯកសារ-កាលប្បវត្តិ



ចដើរយេឃើទង័អ ក៏មសិទ្ធចដើរយេឃើទ ចម្មមុំយេចិក្តឹលយេទះ
ចដើរយេឃើទង័អ ក៏មសិទ្ធចដើរយេឃើទះប៉ចូមុំយ ចដើរយេចពិ៧០ មង្វ៉ាទះយេប្លស្ទិ
១៤០៣ឆ្នាំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ លើផ្ទៃដីសរុបចំនួន **៥៨៣** (**ប្រាំរយ ប៉ែតសិប ប្រាំបី**)ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តកំពង់ធំ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ស្រី បញ្ញា អភិវឌ្ឍន៍ ខូអិលធីឌី** ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ១១៧៣ សជណ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ និងខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*__កន្លែងទទួល:__*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  __"ដើម្បីគោរពជូនជ្រាប"__
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២១៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ១៩១៥,៧០ ហិកតា ស្ថិតក្នុងសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនិតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៤២ សជណ.ចក ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## **សម្រេច**

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ទីតាំងដី ១ កន្លែងមានទំហំ **១៩១៥,៧០** (មួយពាន់ប្រាំបួនរយដប់ប្រាំក្បៀសចិតសិប) ហិកតា នៅក្នុងសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ UTM_ Zone 48 N, Datum: WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|---|---|---|
| 0 | 617441 | 1514103 | 11 | 613607 | 1505850 | 22 | 616130 | 1507235 |
| 1 | 613878 | 1512343 | 12 | 612781 | 1503836 | 23 | 616200 | 1507883 |
| 2 | 614209 | 1511621 | 13 | 612128 | 1503329 | 24 | 616595 | 1509026 |
| 3 | 614577 | 1510999 | 14 | 613075 | 1502258 | 25 | 616673 | 1509505 |
| 4 | 614625 | 1510764 | 15 | 613415 | 1501925 | 26 | 617202 | 1510337 |
| 5 | 614559 | 1510325 | 16 | 613951 | 1502320 | 27 | 617279 | 1510789 |
| 6 | 614637 | 1509556 | 17 | 615100 | 1502778 | 28 | 617752 | 1511402 |
| 7 | 614153 | 1507920 | 18 | 615199 | 1503427 | 29 | 617949 | 1511825 |
| 8 | 614484 | 1507861 | 19 | 615820 | 1505444 | 30 | 618034 | 1512587 |
| 9 | 614069 | 1506860 | 20 | 616299 | 1505881 | | | |
| 10 | 613360 | 1506021 | 21 | 616384 | 1506572 | | | |

**មាត្រា ២.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ១៩១៥,៧០ (មួយពាន់ប្រាំបួនរយដប់ប្រាំក្បៀសចិតសិប) ហិកតា ដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះ ដែលជាដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ។

**មាត្រា ៣.~**

ត្រូវបានប្រគល់អណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា ២ ខាងលើនេះ ជូនអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែងជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ និងសម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ។

**មាត្រា ៤.~**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សមាជិក គសសជ
- អគ្គលេខាធិការដ្ឋាន គសសជ
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

[illegible]

[illegible] ស្ទឹងត្រែង ខេត្តស្ទឹងត្រែង

[illegible]




| | | |
|---|---|---|
| 1 | [illegible] | [illegible] |
| 2 | [illegible] | [illegible] |
| 3 | [illegible] | [illegible] |
| 4 | [illegible] | [illegible] |
| 5 | 614559 | 1510325 |
| 6 | 614617 | [illegible] |
| 7 | [illegible] | 1507970 |
| 8 | 614464 | 1507861 |
| 9 | 614069 | 1506800 |
| 10 | 613360 | 1506021 |
| 11 | [illegible] | 1505850 |
| 12 | 612781 | 1503836 |
| 13 | 612128 | 1503329 |
| 14 | 613075 | [illegible] |
| 15 | 613415 | 1501525 |
| 16 | 613951 | 1502320 |
| 17 | 615100 | 1502779 |
| 18 | 615199 | 1503427 |
| 19 | 615820 | 1505444 |
| 20 | 616299 | 1505881 |
| 21 | 616384 | 1506572 |
| 22 | 616130 | 1507235 |
| 23 | 616200 | 1507883 |
| 24 | 616595 | 1509026 |
| 25 | 616673 | 1509505 |
| 26 | 617202 | 1510337 |
| 27 | 617279 | 1510789 |
| 28 | 617752 | 1511402 |
| 29 | 617949 | 1511825 |
| [illegible] | [illegible] | 1512587 |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:១០៨៧.អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់លោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក **អេត និត** ជាជំនួយការលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ជំនួសលោក **ច័ន្ទ តារា** ដែលត្រូវទទួលភារកិច្ចថ្មី។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចប្រការ ៣*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ**១០៩៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការបង្កើតគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ សម្រាប់អាណត្តិទី៤ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១ | លោក | **សុខ ឫទ្ធី** | ប្រធានអគ្គនាយកនៃគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ | ប្រធាន |
| ២. | លោកជំទាវ | **ទន់ សាអ៊ីម** | អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣. | លោក | **ទេត មុន្នី** | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៤. | លោក | **ចន វណ្ណៈ** | ប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ចនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០៧៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

**សម្រេច**

**មាត្រា ១:** ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម៖

១- លោក **នុច សុខសម្បត្តិ**

២- លោក **ឌី ឡាំថា**

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៨៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

---

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យ លេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរទន្លេសាប

**សម្រេច**

**មាត្រា ១:** ត្រូវបានតែងតាំងលោក **ខូច មាស** ជាប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ជំនួសលោក **ម៉េង មុនីរក្ស** ដែលត្រូវបានទទួលភារកិច្ចថ្មី ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១០៩៥.អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា១** : ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលរបស់ក្រសួងទេសចរណ៍ ទៅក្នុងឋានន្តរសក្តិក្រមការ នៃក្របខណ្ឌមន្ត្រីក្រមការ គិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ តទៅ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | នាម និងគោត្តនាម | ភេទ | ឋានន្តរសក្តិ | ថ្នាក់ |
|---|---|---|---|---|
| ១ | **ហ៊ុន ពិសី** | ប | មន្ត្រីក្រមការ | **ថ្នាក់លេខ ១៤** |
| ២ | **ម៉ី មុន្នីថ្នា** | ស | មន្ត្រីក្រមការ | **ថ្នាក់លេខ ១៤** |

| | | | | |
|---|---|---|---|---|
| ៣ | **ស៊ិន គឹមហៀង** | ប | មន្ត្រីក្រមការ | ថ្នាក់លេខ ១៤ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*ដូចមាត្រា ២*
*រាជកិច្ច*
*ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ជូនអនុព័ន្ធយោធាសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និងអនុព័ន្ធយោធាសាធារណរដ្ឋបារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលមានស្នាដៃល្អក្នុងការសហប្រតិបត្តិការជាមួយកងយោធពលខេមរភូមិន្ទ សម្រេចទទួលបានលទ្ធផលល្អប្រសើរដូចមានរាយនាមខាងក្រោម៖

**ក.មេដាយសហមេត្រី ថ្នាក់ សេនា**

-លោកឧត្តមសេនីយ៍ត្រី **ថាន់ ទិន** (THAN WIN) នាយការិយាល័យអនុព័ន្ធយោធាសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

**ខ.មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ**

-លោកវរនាវីត្រី **ហ្សេរ៉ូម ឆាដុង** (JEROME CHARDON) នាយការិយាល័យអនុព័ន្ធយោធាសាធារណរដ្ឋបារាំង

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កញ្ញា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៨៥. អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនបុគ្គលិកក្រុមហ៊ុន ភ្នំពេញអេសអ៊ីហ្សិត អិលធីឌី ចំនួន០៥រូប ដែលបានខិតខំប្រឹងប្រែងលះបង់ទាំងកម្លាំងកាយចិត្តប្រាជ្ញាស្មារតីនិងធនធានផ្ទាល់ខ្លួនចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាងនិងអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនៃប្រទេសជាតិ ជាពិសេសបាននិងកំពុងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ស្ថិតនៅក្នុងសង្កាត់អង្គស្នួល ខណ្ឌដង្កោ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

១-លោកបណ្ឌិត Rikuo Katsumata
២-លោក Hiroshi Uematsu
៣-លោក Sim Swee Choon David
៤-លោក Fong Nee Wai

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

-អ្នកនាង Yumi Ishimoto

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០៨៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់សេនា** ជូនលោក **ជើរី វង់ (Dr. JERRY WONG)** ប្រធានអង្គការសេវាសង្គម Happy Tree ដែលមានគុណបំណាច់ និងស្នាដៃល្អក្នុងការជួយកសាងមណ្ឌល Happy Land ដើម្បីជួយដល់ការអភិវឌ្ឍន៍ កងយោធពលខេមរភូមិន្ទ។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ១០៩០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយសហមេត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស / រកត / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៤ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនយោធាចារ្យ បញ្ជាការដ្ឋានអង្គរក្ស នៃ សាធារណរដ្ឋឥណ្ឌូនេស៊ី ចំនួន ០៤ រូប ដែលមានស្នាដៃល្អក្នុងការជួយហ្វឹកហ្វឺនជំនាញអង្គរក្សពិសេស ដល់នាយទាហាន និង ពលទាហាន នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនមិត្តភាព កម្ពុជា - ឥណ្ឌូនេស៊ី ក្រាំងចេក បញ្ជាការដ្ឋានអង្គរក្ស នៃ ព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- លោក | COL | MOHAMAD SJABAN LANTAN | នាយកសាលាក្រុម C បញ្ជាការដ្ឋានអង្គរក្ស នៃសាធារណរដ្ឋ ឥណ្ឌូនេស៊ី |
| ២- លោក | MAJOR | MULYANI | ប្រធាន យោធាចារ្យឥណ្ឌូនេស៊ី |
| ៣- លោក | CAPT | TANDRA WIDERU | យោធាចារ្យឥណ្ឌូនេស៊ី |
| ៤- លោក | LETTU | KHAERUL BHAKTI | យោធាចារ្យឥណ្ឌូនេស៊ី |

**មាត្រា២ .**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៩១ . អនក្រ.[illegible]

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សម្រេច

**មាត្រា ១.**

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីនៃអគ្គនាយកដ្ឋានកាំកុងត្រូលក្រសួងពាណិជ្ជកម្ម ចំនួន០៧រូប មានស្នាដៃល្អ ចូលរួមចំណែកយ៉ាងសកម្មក្នុងការស្ថាបនាបន្ទប់មន្ទីរពិសោធន៍ថ្មី មានសមត្ថភាពខ្ពស់និងស្តង់ដារត្រឹមត្រូវ ដែលមានលទ្ធភាពស្រាវជ្រាវវិភាគរកសារធាតុមេឡាមីនក្នុងម្ហូបអាហារ និងដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់ ការពារសុខុមាលភាពប្រជាជន ទប់ស្កាត់បង្ក្រាបរាល់បទល្មើស ធ្វើចរាចរទំនិញក្លែងក្លាយ ខូចគុណភាព សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ:**

១-លោក **ផុន លីសក្កដា** ប្រធានការិយាល័យវិភាគប្រេងឥន្ធនៈ នៃនាយកដ្ឋានមន្ទីរពិសោធន៍

២-លោក **តុន ឃីហេង** អនុប្រធានការិ.វិភាគមីក្រូជីវសាស្ត្រម្ហូបអាហារ នៃនាយកដ្ឋានមន្ទីរពិសោធន៍

៣-លោក **ឆាយ ផល្លរ័ត្ន** អនុប្រធានការិ.វិភាគរូបសាស្ត្រ នៃនាយកដ្ឋានមន្ទីរពិសោធន៍

៤-លោកស្រី **ស្រេង សុខលី** អនុប្រធានការិ.វិភាគប្រេងឥន្ធនៈ នៃនាយកដ្ឋានមន្ទីរពិសោធន៍

**ខ-មេដាយប្រាក់ការងារ:**

១-លោក **ហោ ឆាយ** ប្រធានការិ.គ្រប់គ្រងកិច្ចធានាមន្ទីរពិសោធន៍ នៃនាយកដ្ឋានមន្ទីរពិសោធន៍

២-លោកស្រី **យស់ សុវណ្ណារី** អនុប្រធានការិ.គ្រប់គ្រងកិច្ចធានាមន្ទីរពិសោធន៍ នៃនាយកដ្ឋានមន្ទីរពិសោធន៍

៣-លោក **ឃី ចាន់ឌី** មន្ត្រីនាយកដ្ឋានមន្ទីរពិសោធន៍

**មាត្រា ២.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១០១៤៧. អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីកាំកុងត្រូល និងមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ចំនួន១១រូប មានស្នាដៃល្អ ចូលរួមចំណែកយ៉ាងសកម្មក្នុងការស្ថាបនាបន្ទប់មន្ទីរពិសោធន៍ថ្មី មានសមត្ថភាពខ្ពស់និងស្តង់ដារត្រឹមត្រូវ ដែលមានលទ្ធភាពស្រាវជ្រាវវិភាគរកសារធាតុមេឡាមីនក្នុងម្ហូបអាហារ និងដើម្បីការពារផលប្រយោជន៍អ្នកប្រើប្រាស់ ការពារសុខុមាលភាពប្រជាជន ទប់ស្កាត់បង្ក្រាបរាល់បទល្មើស ធ្វើចរាចរទំនិញក្លែងក្លាយ ខូចគុណភាព សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ:**

១-លោក ស៊ុំ ណារុន   អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូល
២-លោក ចម បូរិន្ទ   អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូល

**ខ-មេដាយសុវត្ថារា ថ្នាក់ សេនា:**

១-លោក ឌឹម ថេង   ប្រធានអគ្គនាយកដ្ឋានមន្ទីរពិសោធន៍
២-លោក ស៊ិន ស៊ីដេត   អនុប្រធាននាយកដ្ឋានមន្ទីរពិសោធន៍
៣-លោក លឿង រដ្ឋា   អនុប្រធាននាយកដ្ឋានដោះស្រាយវិវាទ និងគោលនយោបាយទូទៅ

**គ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ:**

១-លោក គីម មាសសុខសីហា   ប្រធាននាយកដ្ឋានកិច្ចការការពារអ្នកប្រើប្រាស់និងបង្ក្រាបការក្លែងបន្លំ
២-លោក ជាន អូន   អនុប្រធាននាយកដ្ឋានបច្ចេកទេសនិងទំនាក់ទំនងសាធារណៈ

| | | | |
|---|---|---|---|
| ៣-លោក | ម៉ម | ទិឆ្យាមុនី | អនុប្រធាននាយកដ្ឋានមន្ទីរពិសោធន៍ |
| ៤-លោក | ជា | អ៊ាកឃីម | អនុប្រធាននាយកដ្ឋានមន្ទីរពិសោធន៍ |
| ៥-លោក | ស៊ុំ | សុខុម | អនុប្រធានសាខាកាំកុងត្រូលខេត្តព្រះសីហនុ |
| ៦-លោកស្រី | ទន្សៃ | ណារី | អនុប្រធានសាខាកាំកុងត្រូលផែស្ងួត-ចុងទីក្រុងភ្នំពេញ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៩៣ អនក្រ.បក

# អនុក្រឹត្យ

# ស្ដីពី

# ការដំឡើងឋានន្តរស័ក្ដិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្ដិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **សោម គិរម្យ** អត្តលេខ ១១៨៩១

២- លោកវរសេនីយ៍ទោ **ស៊ឹម សាវ៉ាត់** អត្តលេខ ០៧៨១២

៣- លោកវរសេនីយ៍ទោ **អែម សារិន** អត្តលេខ ០៥១៣៦

៤- លោកវរសេនីយ៍ទោ **សុខ មិន** អត្តលេខ ០៥២៧១

៥- លោកវរសេនីយ៍ទោ **ធុច ខេមរិន្ទ** អត្តលេខ ០៣៩៩៨

៦- លោកស្រីវរសេនីយ៍ទោ **ហួត យ៉ាន** អត្តលេខ ០៥៤៤១

៧- លោកស្រីវរសេនីយ៍ទោ **អៃ សុខម៉ា** អត្តលេខ ០២២៩១ ៕

៨- លោកវរសេនីយ៍ទោ **ព្រុំ សន្ធរ** អត្តលេខ ៦៨២៣៩

៩- លោកវរសេនីយ៍ទោ **សោម ផា** អត្តលេខ ៣៣២៨១

១០- លោកវរសេនីយ៍ទោ **សៀង ឌឿន** អត្តលេខ ០៦២៦៥

១១- លោកវរសេនីយ៍ទោ **សៅ សារឹម** អត្តលេខ ០៦២៤៥ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ...

រាជធានីភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ៦៣០ /៩៨ ក.អ.ក ចុះថ្ងៃទី១២.០៣.១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស្ព័រតិច អ៊ិនឌឹសស្ទ្រីយ៍ ចុះថ្ងៃទី០៥.០៧.២០១១

## ស ម្រេ ច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ស្ព័រតិច អ៊ិនឌឹសស្ទ្រីយ៍ តំណាងដោយ លោក YU. SHENG-CHUN សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 216725834 ចុះថ្ងៃទី២៥.១១.២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ # 11. YUAN YI Street, TAOYUAN City, TAOYUAN SHIEN- TAIWAN R.O.C ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខចុះបញ្ជីផលិតផល** ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone 855-23-... Fax 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" ស្ព័រតិច អ៊ិនឌឹសស្ទ្រីយ៍ "*
*" ( SPORTEX INDUSTRY CO., LTD. ) "*

**ទីតាំងរោងចក្រ ៖** *" ផ្លូវជាតិលេខ៥ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

**ប្រការ២.** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ **ពីមុខ** រោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** ប្រកាសលេខ៣៥៧ ឧក.ប្រក ចុះថ្ងៃទី២៧.០៥.១៩៩៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ ចាក់សម្លៀកបំពាក់ របស់ក្រុមហ៊ុន ស្ព័រតិច អ៊ិនឌឹសស្រ្ទីយ៍ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៦:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សាលារាជធានីភ្នំពេញ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"

ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ០៨៥១.១១៥.ឧរម.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ១៣៨៥ /១១ គ.វ.ក ចុះថ្ងៃទី២៧.០៦.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន និច-ធី អឹកែរីល (ខេមបូឌា) ចុះថ្ងៃទី០៧.០៦.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន និច-ធី អឹកែរីល (ខេមបូឌា) តំណាងដោយ លោក JUNG YOON SUK សញ្ជាតិកូរ៉េ អាយុ៥៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M82434366 ចុះថ្ងៃទី០៦.១២.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ 16-1502, Rich Garden Malao Road, Gubei Shanghai, China. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខចុះបញ្ជីផលិតផល** ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ : ៨៥៥-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" និច-ធី អីភែរីល (ខេមបូឌា)"*
*"(NEX-T APPAREL CO., LTD.)"*

**ទីតាំងរោងចក្រ ៖** *"ភូមិម៉ែល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

